00154468
Declassified to Public
06 September 2012

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## នៅក្នុងអង្គបុរេជំនុំជម្រះនៃ
## អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

នៅក្នុងប្រធានបទពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ កាំង ហ្កេកអ៊ាវ (ឌុច)
ប្តឹងប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន
របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

សំណុំរឿងលេខ ០០២/១៤-០៨-២០០៦

សារណារបស់ អែន ហេនដែល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
ក្នុងនាមការបញ្ចេញយោបល់ផ្ទាល់ខ្លួន
៤ តុលា ២០០៧

Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
DC-Cam • 66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
Tel: (855-23) 211-875 • Fax: (855-23) 210-358 • dccam@online.com.kh • www.dccam.org

00154469

## សេចក្តីសង្ខេប

សារណានេះត្រូវបានធ្វើឡើង ដោយអនុលោមតាមសេចក្តីជូនដំណឹងជាសាធារណៈរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ ដែលអនុញ្ញាតឲ្យមានការដាក់ជូនសារណាដោយអ្នកមិនមែនជាភាគីក្នុងរឿងក្តី យោងតាមវិធាន៣៣នៃវិធានផ្ទៃក្នុង ។ សារណានេះនឹងដោះស្រាយការរកឃើញដោយសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលថា "ពួកគេមិនមានយុត្តាធិការដើម្បីសម្រេចភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុច" ដោយតុលាការយោធាកម្ពុជាទេ ។ ជាវិបាក សារណានេះមិនពិភាក្សាអំពីច្បាប់ដែលមានអនុភាពលើការសម្រេចថា តើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់ឌុចត្រូវបានរំលោភ ឬអត់នោះទេ ហើយសារណានេះក៏មិនបញ្ចេញយោបល់ទាក់ទងនឹងចំណុចសួរមួយ ថាតើឌុចមានសិទ្ធិទទួលបាននូវការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ឬទទួលបានដំណោះស្រាយផ្សេងពីនេះដែរឬទេ ។

ឌុចបានប្តឹងឧទ្ធរណ៍ជំទាស់នឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នក្រោមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងកំពុងស្វែងរក "ការដោះលែងភ្លាមៗ" ដោយគ្មានលក្ខខណ្ឌ ឬដោយបង់ប្រាក់ធានា ។ ដីកាឃុំខ្លួនបណ្តោះអាសន្នបានពិចារណាដល់ទ្រឹស្តីចំនួនពីរ ដែលតាមរយៈទ្រឹស្តីទាំងពីរនេះ ការឃុំខ្លួនកាលពីមុនរបស់ឌុចអាចទំនងជាបណ្តាលឲ្យអង្គជំនុំជម្រះទាំងឡាយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បាត់បង់ដែនយុត្តាធិការលើបុគ្គលរបស់ខ្លួន ។ ដោយរកឃើញថា ទ្រឹស្តីទាំងពីរនេះមិនមានអនុភាពអនុវត្តនៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា នៅក្នុងដំណាក់កាលជំនុំជម្រះនាពេលនេះខ្លួនមិនមានយុត្តាធិការដើម្បីសម្រេចអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុចឡើយ ក៏ប៉ុន្តែក៏មិនបានច្រានចោលនូវលទ្ធភាពដែលថា ឌុចអាចនឹងទទួលបាននូវដំណោះស្រាយនៅក្នុងសាលក្រមចុងបញ្ចប់ ។ សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញនូវទ្រឹស្តីផ្សេងៗទៀតដែលអាចជួយដល់ខ្លួន ដូចជាថាតើឌុចត្រូវបានដាក់ឃុំឃាំងខ្លួននៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្នដែល "ទើបនឹងកសាងឡើង" របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងស្ថានភាពយ៉ាងម៉េចដែរ ។ ជាងនេះទៅទៀត ដោយសារតែសហចៅក្រមស៊ើបអង្កេតមិនបានពិនិត្យមើលអំពីចរិកគតិយុត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលជាស្ថាប័នវិសាមញ្ញដូចឈ្មោះរបស់វា ដែលមកពីពាក្យឡាតាំង sui generis សហចៅក្រមមិនបានគិតដល់ថា តើអង្គជំនុំជម្រះវិសាមញ្ញមានកាតព្វកិច្ចដូចគ្នា ឬ ស្រដៀងគ្នាទៅនឹងតុលាការកម្ពុជាដើម្បីដោះស្រាយបញ្ហារំលោភបំពានលើដំណើរការជំនុំជម្រះត្រឹមត្រូវដែរឬទេ ។ នៅចុងបញ្ចប់ ទាំងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀតបាន

00154470

បង្ហាញថា សូម្បីតែការរំលោភបំពានលើសិទ្ធិរបស់ឌុចមិនមែនបណ្ដាលមកពីអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ នៅក្នុងការពិចារណាអំពីការឃុំឃាំងបណ្ដោះអាសន្នត្រឹមត្រូវឬមិនត្រឹមអង្គជំនុំជម្រះនេះមានទាំងអំណាច និងកាតព្វកិច្ចនៅក្នុងការពិចារណាអំពីភាពស្របច្បាប់ឬមិនស្របច្បាប់ និងរយៈពេលនៃការឃុំខ្លួនកាលពីមុនរបស់ឌុច ។

## អ្នកផ្ដល់សារណា

បច្ចុប្បន្ន អែន ហេនដែល ជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ អែន ហេនដែល ធ្លាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អស់រយៈពេលជាង១០ឆ្នាំ និងជាសមាជិកនៃគណៈមេធាវីរបស់រដ្ឋកាលីហ្វញ៉ា នៅសហរដ្ឋអាមេរិក ។ យោបល់ដែលបញ្ចេញនៅក្នុងសារណានេះគឺជាយោបល់ផ្ទាល់ខ្លួន ហើយការយល់ឃើញទាំងនេះគឺមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ ។

## I. ការទទួលខុសត្រូវរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះការរំលោភបំពានលើការឃុំខ្លួនបណ្ដោះអាសន្នដោយតុលាការកម្ពុជា អាចអាស្រ័យលើលក្ខណៈគតិយុត្តិរបស់ខ្លួន

### ក) អង្គជំនុំជម្រះវិសាមញ្ញជាតុលាការជាតិដែលមានលក្ខណៈអន្តរជាតិ

១) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដោយអនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតជា“មូលដ្ឋានគតិយុត្តិ និងគោលការណ៍ និងបែបបទសម្រាប់...សហប្រតិបត្តិការ[របស់ពួកគេ]” ។ ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះត្រូវបានអនុម័តឲ្យទៅជាច្បាប់កម្ពុជាដោយអង្គនីតិបញ្ញត្តិ និងត្រូវបានយកទៅអនុវត្តតាមរយៈការអនុម័តច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយអនុលោមតាមកិច្ចព្រមព្រៀងនិងច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងជាផ្នែកមួយនៃ“រចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់” ដោយ“មានជំនួយពីអន្តរជាតិ” ។

២) ដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញជាតុលាការកម្ពុជាដែលបង្កើតឡើងដោយអនុលោមតាមច្បាប់កម្ពុជា ។ ប៉ុន្តែលក្ខណៈខ្លះៗរបស់អង្គជំនុំជម្រះវិសាមញ្ញមានភាពដូចគ្នាទៅនឹងតុលាការអន្តរជាតិដែរ ។ ដោយសារមូលហេតុនេះ លោកឧបនាយករដ្ឋមន្ត្រីកម្ពុជា សុខ អាន បានហៅអង្គជំនុំជម្រះវិសាមញ្ញថា ជា“តុលាការ

00154471

ជាតិដែលមានលក្ខណៈអន្តរជាតិ» ។ លោកឧបនាយករដ្ឋមន្ត្រីបានធ្វើការកត់សម្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញជា«តុលាការចម្រុះ ឬតុលាការកូនកាត់ដែលស្ថិតនៅក្នុងតុលាការជាតិក៏ប៉ុន្តែមានការប្រើប្រាស់ទាំងច្បាប់ជាតិ និងអន្តរជាតិ មានចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកទាំងជាតិ និងអន្តរជាតិ និងប្រើប្រាស់ហិរញ្ញវត្ថុជាតិ និងអន្តរជាតិ» ។

៣) លក្ខណៈគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ ទោះជាតុលាការជាតិ ឬតុលាការអន្តរជាតិ ឬជាអ្វីមួយនៅចន្លោះកណ្តាលនេះក៏ដោយ ក៏នៅតែមានសារៈសំខាន់ដដែល ព្រោះវាអាចមានឥទ្ធិពលទៅលើបញ្ហាមួយចំនួនដែលអាចកើតឡើងនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញនេះ ដែលរួមទាំងការទទួលខុសត្រូវរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការដោះស្រាយចំពោះការរំលោភបំពានលើសិទ្ធិរបស់លោក កាំង ហ្គេកអ៊ាវ (ឌុច) នៅខណៈពេលដែលបុគ្គលនេះត្រូវបានឃុំខ្លួនដោយតុលាការយោធាអស់រយៈពេល៨ឆ្នាំដោយមិនធ្វើការជំនុំជម្រះទោស ។ តាមការពិត នៅពេលដែលចេញដីកាឃុំខ្លួនបណ្តោះអាសន្នប្រឆាំងនឹងឌុចដោយអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេតបានសង្កត់ធ្ងន់ថា បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញ «ត្រូវបានបង្កើតឡើងនៅក្នុងអង្គការ តុលាការកម្ពុជាក៏ដោយ...[អង្គជំនុំជម្រះវិសាមញ្ញ]ជាស្ថាប័នឯករាជ្យដែលមានរចនាសម្ព័ន្ធដាច់ដោយឡែកពីយុត្តាធិការជាតិដទៃទៀត» ។ ជាលទ្ធផល នៅក្នុងការសម្រេចអំពីសមត្ថកិច្ចនៅក្នុងការជំនុំជម្រះអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុច សហចៅក្រមស៊ើបអង្កេតមិនបានគិតដល់កាតព្វកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញដែលជាតុលាការកម្ពុជាក្នុងស្រុកទេ ។

៤) នៅក្នុងការវាយតម្លៃអំពីលក្ខណៈគតិយុត្តិរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ដែលត្រូវបានគេគិតថាជាតុលាការកូនកាត់ដូចគ្នាដែរ អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការនេះបានគិតគូដល់ទិដ្ឋភាពមួយចំនួននៃទំនាក់ទំនងរបស់តុលាការពិសេសនេះទៅនឹងសហគមន៍អន្តរជាតិមុនពេលដែលចេញសេចក្តីសម្រេចថា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូននេះជាតុលាការអន្តរជាតិ ។ អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការពិសេសនេះបានកត់សម្គាល់ថា តុលាការពិសេសនេះជា«យុត្តាធិការថ្មីមួយមានដំណើរការនៅក្នុងមជ្ឈដ្ឋានច្បាប់អន្តរជាតិ» ដែល«មានសមត្ថកិច្ចជំនុំជម្រះ» តាមរយៈសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិ និងសេរ៉ាលីអូន ។ ដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូននេះបានចេញសេចក្តីសម្រេចថា តុលាការនេះជា«ស្ថាប័នស្វយ័ត និងឯករាជ្យ» និងមិនមែនជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌ក្នុងស្រុករបស់សេរ៉ាលីអូនទេ ។ បើយើងធ្វើការប្រៀបធៀបដូចដែលបានពិភាក្សាពីខាងលើ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាយុត្តាធិការថ្មីដែលបង្កើតឡើងដោយយោងទៅតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាផង និងជាតុលាការកម្ពុជាដែលបង្កើតឡើងដោយយោងទៅតាមច្បាប់កម្ពុជាផង ។ ថ្វីបើអង្គជំនុំជម្រះវិសាមញ្ញមាន

00154472

យុត្តាធិការពិសេស រចនាសម្ព័ន្ធឯករាជ្យ និងមានបុគ្គលិកអង្គការសហប្រជាជាតិក៏ដោយ ក៏ស្វ័យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញដាច់ពីប្រព័ន្ធយុត្តិធម៌កម្ពុជាគឺមិនច្បាស់លាស់ទេ ។ ឧទាហរណ៍ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ផ្តល់ឲ្យតុលាការពិសេសយ៉ាងច្បាស់លាស់ នូវឧត្តមភាពផ្នែកយុត្តាធិការខ្ពស់ជាងតុលាការជាតិរបស់សេរ៉ាលីអូន ចំណែកឯច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ គឺមិនបានចែងអំពីទំនាក់ទំនងជាឋានានុក្រមរវាងអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការកម្ពុជាផ្សេងទៀតឡើយ ។ នៅខណៈពេលដែលតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូនទទួលបានអណត្តិឲ្យអនុវត្តវិធានទាំងឡាយដែលនៅជាធរមានឡើយ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងឲ្យធ្វើវិសោធនកម្មវិធានទាំងនោះ ឬឲ្យអនុម័តវិធានថ្មីមួយតាមការចាំបាច់នោះ បែរជានីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែ«ស្របទៅនឹងច្បាប់កម្ពុជា» ដោយមានការស្វែងរកការណែនាំពីវិធាននីតិវិធីអន្តរជាតិ នៅពេលដែលមានការខ្វះចន្លោះកើតឡើង ដូចជា ភាពមិនច្បាស់លាស់នៅក្នុងការបកស្រាយ ឬក៏បញ្ហាទាក់ទងនឹងភាពសមស្រប ឬមិនសមស្របជាមួយបទដ្ឋាននីតិវិធីអន្តរជាតិតែប៉ុណ្ណោះ ។

៥) ចំណុចខុសគ្នាផ្សេងៗទៀតរវាងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន និងអង្គជំនុំជម្រះវិសាមញ្ញនោះគឺការកម្រិតនៃឯករាជ្យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញដាច់ពីកម្ពុជា ។ ខណៈពេលដែលតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូនមាន«លទ្ធភាពអាចចុះកិច្ចព្រមព្រៀងជាមួយនីតិបុគ្គលអន្តរជាតិផ្សេងៗដែលគ្រប់គ្រងដោយច្បាប់អន្តរជាតិបាន» បែរជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហាក់ដូចជាមិនមានអំណាចបែបនេះទៅវិញ ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ផងដែរនោះគឺការណ៍ដែលថាលក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ហាមប្រាមមិនឲ្យមានការស្នើសុំការលើកលែងទោសចំពោះបុគ្គលណាមួយពីបទឧក្រិដ្ឋកម្មអន្តរជាតិ ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការពិសេសនេះឡើយ ។ ចំណែកឯអង្គជំនុំជម្រះវិសាមញ្ញវិញគឺចែងត្រឹមតែថា «វិសាលភាពនៃការលើកលែងទោស ...ដែលត្រូវបានផ្តល់ឲ្យមុនពេលអនុម័តច្បាប់នេះ នឹងត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ» ។ នេះអាចបង្ហាញអំពីភាពមិនច្បាស់លាស់របស់អង្គការសហប្រជាជាតិទាក់ទងនឹងលក្ខណៈគតិយុត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលនៅក្នុងពេលថ្មីៗកន្លងមកនេះអង្គការសហប្រជាជាតិបានប្រកាន់យកនូវគោលជំហររឹងមាំមួយប្រឆាំងនឹងការផ្តល់ការលើកលែងទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ។ចុងក្រោយបង្អស់ខុសប្លែកពីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ប្រសិនបើបុគ្គលិកអង្គការសហប្រជាជាតិ«ខកខានមិនបាន ឬបដិសេធន៍មិនចូលរួម» នៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬប្រសិនបើអង្គការសហប្រជាជាតិត្រូវដកការគាំទ្ររបស់ខ្លួនចេញពីអង្គជំនុំជម្រះវិសាមញ្ញ ហើយមិនមានបេក្ខជនបទេសដើម្បី

00154473

បំពេញតួនាទីទំនេរទាំងនោះ  រដ្ឋាភិបាលកម្ពុជាប្រហែលជាអាចរើសបេក្ខជនកម្ពុជាមកបំពេញជំនួស» ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានមើលឃើញជាមុនអំពីលទ្ធភាពដែលថា នៅក្រោមលក្ខខណ្ឌខ្លះ អង្គជំនុំជម្រះវិសាមញ្ញអាចបន្តដំណើរការរបស់ខ្លួនដោយគ្មានការគាំទ្រពីអន្តរជាតិ ឬដោយគ្មានបុគ្គលិកអន្តរជាតិ ។

៦) ម្យ៉ាងវិញទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូនដែរ ត្រូវបានគេគិតថាជាយន្តការយុត្តិធម៌អន្តរជាតិមួយ ។ ឧទាហរណ៍ សាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន បានបង្ហាញអំពីការណ៍ដែលថា សន្ធិសញ្ញាបង្កើតតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូនគឺជាកិច្ចព្រមព្រៀងក្នុងនាម«សមាជិក*ទាំងអស់*នៃអង្គការសហប្រជាជាតិជាមួយប្រទេសសេរ៉ាលីអូន» ដូច្នេះ សន្ធិសញ្ញានេះជា«ឆន្ទៈរបស់សហគមន៍អន្តរជាតិ» ។ សាលាឧទ្ធរណ៍នៃតុលាការពិសេសនេះបានសម្រេចថា «អំណាចគតិយុត្តដែលអនុវត្តដោយតុលាការពិសេសនេះគឺមិនមែនជារបស់ប្រទេសសេរ៉ាលីអូនទេ ប៉ុន្តែ អំណាចគតិយុត្តរបស់តុលាការពិសេសនេះគឺឆ្លុះបញ្ចាំងអំពីផលប្រយោជន៍របស់សហគមន៍អន្តរជាតិ» ។ ស្រដៀងគ្នាដែរ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា គឺជាលទ្ធផលនៃការចចារអន្តរជាតិអស់រយៈពេលជាច្រើនឆ្នាំ ហើយអាចចេញរូបដោយសារតែមានការជម្រុញពីមហាសន្និបាតអង្គការសហប្រជាជាតិតែប៉ុណ្ណោះ ។

៧) ជាងនេះទៅទៀត ដូចតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូនដែរ អង្គជំនុំជម្រះវិសាមញ្ញអាចនិយាយបានថា គឺបង្កើតឡើងដើម្បី«បំពេញកិច្ចការជាអន្តរជាតិ» ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជារបស់អង្គជំនុំជម្រះវិសាមញ្ញបានសង្កត់ធ្ងន់ថា ការណ៍ដែលថា«ការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌ជាតិ និងអន្តរជាតិនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតែជាបញ្ហាព្រួយបារម្ភយ៉ាងសំខាន់*ចំពោះសហគមន៍អន្តរជាតិទាំងមូល*» ។ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានបន្ទរត្រង់ចំណុចនេះថា «ឧក្រិដ្ឋកម្ម[ដោយខ្មែរក្រហម]ត្រូវបានប្រព្រឹត្តឡើងមិនត្រឹមតែប្រឆាំងនឹងប្រជាជនកម្ពុជាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងប្រឆាំងនឹងមនុស្សជាតិទាំងមូលទៀតផង» ។ ដោយសារមូលហេតុនេះ លោកនាយករដ្ឋមន្ត្រីបានមើលឃើញថា វាជារឿង«សមរម្យមួយដែលថា ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ទាំងជាតិ និងអន្តរជាតិ នឹងធ្វើការជាមួយគ្នានៅក្នុងកិច្ចការនាំយកអ្នកទទួលខុសត្រូវខ្ពស់បំផុត និងតាមរយៈការធ្វើដូច្នេះ បានជួយបង្កើតនូវវប្បធម៌មួយដែលនឹងពារការបាននូវការកើតឡើងម្តងទៀតនូវឧក្រិដ្ឋកម្មបែបនេះ នៅកន្លែងផ្សេងៗទៀតនៅក្នុងពិភពលោក» ។

00154474

៨) ដោយសារអង្គជំនុំជម្រះវិសាមញ្ញមិនមែនជាតុលាការជាតិទាំងស្រុង ឬតុលាការអន្តរជាតិទាំងស្រុង អង្គជំនុំជម្រះវិសាមញ្ញនឹងទំនងជាត្រូវពិចារណាអំពីលក្ខណៈគតិយុត្តរបស់ខ្លួន និងច្បាប់មួយណាដែលនឹងត្រូវអនុវត្តទៅតាមសំណុំរឿងនីមួយៗ ។

១) ចំពោះការណ៍ដែលថាអង្គជំនុំជម្រះវិសាមញ្ញជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌កម្ពុជា អង្គជំនុំជម្រះវិសាមញ្ញមានកាតព្វកិច្ចនៅក្រោមច្បាប់សិទ្ធិមនុស្ស ក្នុងការដោះស្រាយបញ្ហារំលោភបំពានផ្សេងៗ ដោយតុលាការកម្ពុជាក្នុងស្រុក ។

៩) ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថាៈ

> សាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យបានសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនៃដំណើរការសមស្របនៃច្បាប់ដូចដែលមានចែងនៅក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

ជាងនេះទៅទៀត ក្នុងនាមជាភាគីសមាជិកមួយរបស់អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋាភិបាលកម្ពុជា រួមទាំងផ្នែកផ្សេងៗរបស់រដ្ឋាភិបាល មានកាតព្វកិច្ច“ គោរព និងធានាដល់បុគ្គលដែលស្ថិតនៅក្នុងទឹកដី និងស្ថិតក្រោមយុត្តាធិការរបស់ខ្លួន នូវសិទ្ធិដែលមានទទួលស្គាល់នៅក្នុង...... អនុសញ្ញា” ដែលរួមទាំងសិទ្ធិទទួលបាននូវការជំនុំជម្រះ“ ដោយគ្មានការពន្យាពេល” ។ ដូច្នេះ រដ្ឋាភិបាលមិនអាចប្រើប្រាស់ច្បាប់ក្នុងស្រុក ដែលរួមទាំងការបែងចែកអំណាចរវាងតុលាការយោធា និងអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធ្វើការដោះសារចំពោះការខកខានមិនបានបំពេញកាតព្វកិច្ចនេះទេ ។ ដូច្នេះ នៅក្នុងកម្រិតដែលថា អង្គជំនុំជម្រះវិសាមញ្ញជាតុលាការជាតិរបស់កម្ពុជា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែ “ផ្តល់ប្រសិទ្ធិភាពទៅឲ្យសិទ្ធិដែលទទួលស្គាល់នៅក្នុង....អនុសញ្ញា” ដែលរួមទាំង“ ធានាថា បុគ្គលដែលទាមទារនូវដំណោះស្រាយ[ដែលមានប្រសិទ្ធិភាព] នឹងទទួលបាននូវការសម្រេចដោយតុលាការ...រដ្ឋអំណាចដែលមានសមត្ថកិច្ច” ។ តាមការពិត គណៈកម្មាការសិទ្ធិមនុស្ស (Human Rights Committee) បានថ្លែងថា តម្រូវការនេះ“គឺមានភាពចាំបាច់ និងមានប្រសិទ្ធិភាពភ្លាមៗ” ។ ដោយសារមូលហេតុនេះៈ

> សិទ្ធិទទួលបាននូវដំណោះស្រាយយ៉ាងមានប្រសិទ្ធិភាពនៅក្នុងករណីខ្លះ អាចតម្រូវឲ្យរដ្ឋជាសមាជិកចែង ឬ ចាត់វិធានការណ៍បណ្តោះអាសន្នដើម្បីចៀសវាងនូវការបន្តការរំលោភ

បំពាន និង ដើម្បីប្រើងប្រែងឲ្យអស់សមត្ថភាពក្នុងការជួសជុលឲ្យបានឆាប់បំផុតនូវការខូចខាតដែល កើតចេញពីការរំលោភបំពាននោះ ។

១០) ដំណោះស្រាយចំពោះការរំលោភបំពានលើសិទ្ធិមនុស្សអាចរួមមានការសងជម្ងឺចិត្ត ការបន្ធូរបន្ថយទោសទណ្ឌ និងការដោះលែង "ដោយពិចារណាទៅលើកម្មវត្ថុ ក៏ដូចជាលក្ខណៈនៃសិទ្ធិដែលត្រូវចោទប្រកាន់ថាបានរំលោភបំពាននោះ" ។ ឧទាហរណ៍ នៅពេលដែលជនជាប់ចោទម្នាក់ត្រូវជាប់នៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេល៥ឆ្នាំដែលដុយគ្នាទៅនឹងនីតិវិធីក្នុងស្រុក គណៈកម្មការសិទ្ធិមនុស្សបានថ្លែងថា បន្ថែមទៅលើទទួលបានសំណងជម្ងឺចិត្ត ជនជាប់ចោទគួរតែត្រូវដោះលែងសិនរង់ចាំសាលក្រមចុងក្រោយ ។ នៅពេលដែលជនជាប់ចោទត្រូវបានឃុំឃាំងរយៈពេល៩ឆ្នាំដោយមិនទទួលបាននូវការជំនុំជម្រះ គណៈកម្មាការសិទ្ធិមនុស្សបានថ្លែងថាៈ

> រដ្ឋជាសមាជិក[របស់អនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ] មានកាតព្វកិច្ចផ្ដល់ឲ្យម្ចាស់ពាក្យបណ្ដឹង[ទៅគណៈកម្មាធិការសិទ្ធិមនុស្ស] នូវដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព ដែលត្រូវមានជាសំណងជម្ងឺចិត្តគ្រប់គ្រាន់សម្រាប់រយៈពេលចំណាយនៅក្នុងការឃុំឃាំមិនស្របច្បាប់ ។ រដ្ឋជាសមាជិកក៏មានកាតព្វកិច្ចផងដែរក្នុងការធានាថាម្ចាស់ពាក្យបណ្ដឹងទទួលបាននូវការជំនុំជម្រះទាន់ពេលវេលា ដោយមាននូវការធានាទាំងឡាយចែងនៅក្នុងមាត្រា១៤ ឬ *ប្រសិនបើមិនអាចធ្វើដូច្នេះទេ ត្រូវដោះលែង*។

**ក) ចំពោះការណ៍ដែលថាអង្គជំនុំជម្រះវិសាមញ្ញជាតុលាការអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិរបស់ឌុច នៅពេលដែលឌុចស្ថិតក្រោម"ការឃុំឃាំងដែលមានប្រយោជន៍"របស់ខ្លួន ។**

១១) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា នៅពេលដែលតុលាការនេះរួមចំណែក"ការឃុំខ្លួនក្នុងមន្ទីរឃុំឃាំងដែលសាងសង់ថ្មី" លើជនជាប់ចោទឃុំឃាំងដោយយុត្តាធិការជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវពិចារណាថា តើការឃុំខ្លួនកាលពីមុនបានរំលោភលើបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិដែរឬទេ ហើយប្រសិនបើមានការរំលោភមែន តុលាការត្រូវផ្ដល់ដំណោះស្រាយសមរម្យ ។ នៅក្នុងសំណុំរឿង*បារ៉ាយ៉ាវីហ្សា* (Barayagwiza Case) ចុងចោទបានប្ដឹង នៅក្នុងចំណោមបញ្ហាផ្សេងទៀត អំពីរយៈពេលឃុំខ្លួនបណ្ដោះអាសន្នរបស់គាត់នៅក្នុងប្រទេស

កាមេរូន មុនពេលត្រូវបញ្ជូនទៅដាក់ក្រោមការឃុំខ្លួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ មុនដំបូង ជនជាប់ចោទត្រូវឃុំខ្លួនក្រោមសំណើរបត្យាប័នរបស់រដ្ឋ ក៏ប៉ុន្តែបន្ទាប់ពីសំណើរទាំងនេះត្រូវទាត់ចោល ប្រទេសកាមេរូនបានឃុំខ្លួនជនជាប់ចោទអស់រយៈពេលជិត៩ខែ តាមរយៈការស្នើសុំដោយព្រះរាជអជ្ញាររបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា មុនពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងបញ្ជូនទៅកាន់សាលាជំនុំជម្រះក្តី ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា ខ្លួនត្រូវតែពិចារណាដល់ "ទំនាក់ទំនងរវាងកាមេរូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ទាក់ទងនឹងការឃុំខ្លួនរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍" ដើម្បីសម្រេចថា តើតុលាការសម្រាប់ប្រទេសរ៉្វាន់ដានេះមានការឃុំខ្លួនដែលមានប្រយោជន៍នេះទៅលើជនជាប់ចោទនៅក្នុងរយៈពេលនេះ ។

១២) យោងទៅតាមសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា "បើទោះបីជាជនជាប់ចោទមិនស្ថិតនៅក្នុងមន្ទីរឃុំឃាំងរបស់តុលាការនេះក៏ដោយ ម្ចាស់បណ្តឹងឧទ្ធរណ៍នេះគឺស្ថិតនៅក្នុងការឃុំខ្លួនរបស់តុលាការ *ប្រសិនបើគាត់ត្រូវបានឃុំខ្លួនដោយយោងទៅតាម*"ដំណើរការ ឬអំណាចស្របច្បាប់" របស់តុលាការនេះ ។ នៅក្នុងករណីនេះ សាលាឧទ្ធរណ៍នេះបានថ្លែងថា "*ប្រសិនបើមិនមាន*"សំណើរបស់ព្រះរាជអាជ្ញាឲ្យមានការឃុំខ្លួនបណ្តោះអាសន្នទេ *បារ៉ាយ៉ាវីហ្សា*ត្រូវគេដោះលែងនៅពេលសំណើបត្យាប័នរបស់រដ្ឋត្រូវបានបដិសេធបាត់ទៅហើយ ។ សាលាឧទ្ធរណ៍នេះបានមើលឃើញស្ថានភាពនោះស្រដៀងទៅនឹងៈ

> ដំណើរការ"ឃាត់ទុក" ដែលតាមរយៈនេះ ដីកាប្រភេទពិសេសមួយ...ត្រូវបានធ្វើឡើងប្រឆាំងទៅនឹងបុគ្គលម្នាក់*ដែលជាប់ឃុំឃាំងរួចហើយ*ដើម្បីធានាថា បុគ្គលនោះនឹងមានវត្តមានចំពោះមុខអជ្ញាធរដែលធ្វើការស្នើសុំ បន្ទាប់ពីការបញ្ចប់រយៈពេលឃុំខ្លួនបច្ចុប្បន្ន ។ "ការឃាត់ទុក"គឺជារបស់ម្យ៉ាង ដែលតាមរយៈនេះ រដ្ឋដែលស្នើសុំអាចទទួលបានការឃុំខ្លួនជនជាប់ឃុំឃាំងនោះ បន្ទាប់ពីបុគ្គលនោះត្រូវបានដោះលែងដោយរដ្ឋដែលឃុំខ្លួនគាត់ ។

នៅក្នុងករណីបែបនេះ តុលាការក្នុងស្រុកបានថ្លែងថា "ជនជាប់ចោទគឺស្ថិតនៅក្នុងការឃុំឃាំងដែលផ្តល់ប្រយោជន៍ដល់រដ្ឋដែលស្នើសុំ ហើយ...រដ្ឋដែលឃុំខ្លួនជនជាប់ចោទដើរតួនាទីជាភ្នាក់ងារសម្រាប់រដ្ឋស្នើសុំដើម្បីគោលបំណង...ជំទាស់[ទៅនឹងភាពស្របច្បាប់នៃការឃុំខ្លួននោះ]" ។ តុលាការក្នុងស្រុកបានសង្កត់

00154477

ធ្ងន់ថា នៅក្នុងសំណុំរឿងនេះដែលកំពុងពិនិត្យមើលឡើងវិញដោយតុលាការ «ទំនាក់ទំនងរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងប្រទេសកាមេរូនគឺកាន់តែខ្លាំងជាងនេះទៅទៀត ដោយសម្អាងទៅលើមូលដ្ឋាននៃកាតព្វកិច្ចអន្តរជាតិ ដែលផ្តល់ឲ្យរដ្ឋដោយក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិក្រោម....ច្បាប់លក្ខន្តិកៈ[បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា]» ។

១៣) ដូចគ្នានេះដែរ នៅក្នុងសំណុំរឿង*ខាជេលីជេលី* (Kajelijeli) សាលាឧទ្ធរណ៍បានពិចារណាដល់ទំនាក់ទំនងរវាងរដ្ឋឃុំខ្លួន និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា នៅក្នុងការសម្រេចអំពីការទទួលខុសត្រូវរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ចំពោះការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទពេលស្ថិតនៅក្នុងការឃុំខ្លួនដោយរដ្ឋនោះ ។ សាលាឧទ្ធរណ៍បានសម្រេចថា «បើទោះបីជាការរំលោភបំពាន [សិទ្ធិរបស់ជនជាប់ចោទ] ពុំបណ្តាលទាំងស្រុងមកពីតុលាការនេះក៏ដោយ ក៏គេដឹងថាគឺអយ្យការដែលជាផ្នែកមួយរបស់តុលាការនេះ ជាស្ថាប័នដែលស្នើសុំដែលទទួលខុសត្រូវសម្រាប់ការជម្រុញឲ្យមានការចាប់ខ្លួននិងការឃុំខ្លួននៅក្នុងប្រទេសបេនីន (Benin)» ។ ដោយសារតែព្រះរាជអាជ្ញា «ខកខានមិនបានបំពេញកាតព្វកិច្ចចោទប្រកាន់របស់ខ្លួនឲ្យបានប្រុងប្រយ័ត្ន» ការរំលោភសិទ្ធិឃុំខ្លួនរបស់ជនជាប់ចោទនៅក្នុងរដ្ឋឃុំខ្លួនគឺបណ្តាលមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ។

១៤) ស្រដៀងគ្នានេះដែរ នៅក្នុងសំណុំរឿង*សេមិនហ្សា* (Semanza) សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា បានថ្លែងថា ការឃុំខ្លួនជនជាប់ចោទនៅក្នុងប្រទេសកាមេរូនអស់រយៈពេលជាង៧ខែតាមរយៈសំណើរបស់អយ្យការ គឺពុំមែនបណ្តាលមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាទេ ។ សាលាឧទ្ធរណ៍នៃតុលាការនេះបានសម្រេចថា រយៈពេលខ្លីមុនពេលផ្ទេរជនជាប់ចោទ ទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា គឺដោយសារតែ«កត្តានយោបាយ និងច្បាប់»ដែលរួមមានគំនៀបសង្កត់ប្រទេសកាមេរូនឲ្យធ្វើបត្យាប័នបុគ្គលនេះទៅកាន់រដ្ឋមួយទៀត និងរង់ចាំការបោះឆ្នោតជាតិ ។ បន្ថែមលើនេះទៀត នៅក្នុងសំណុំរឿង*លូបាងហ្គា* (Lubanga) សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court or ICC) បានថ្លែងថា «ការដឹងតែមួយមុខនៅខាងអយ្យការនូវការស៊ើបអង្កេតដោយអជ្ញាធរ[ជាតិ] គឺមិនបានបង្ហាញភស្តុតាងនៃការចូលរួមដោយអយ្យការនៅក្នុងរបៀបដែលពួកគេធ្វើការស៊ើបអង្កេត ឬមធ្យោបាយផ្សេងៗដែលរួមទាំងការឃុំខ្លួនដែលប្រើប្រាស់ដើម្បីគោលបំណងនេះ» ។ តុលាការនេះក៏បានសង្កត់ធ្ងន់ដែរថា ការឃុំខ្លួនរបស់ជនជាប់ចោទនៅក្នុងរដ្ឋឃុំឃាំងគឺសម្រាប់ឧក្រិដ្ឋកម្មដែល«ខុសគ្នានិងដោយឡែក»ពីបទឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

00154478

១៥) ដូចដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍របស់ឌុច "ចាប់ពីខែកុម្ភៈ ឆ្នាំ២០០២មក ការចោទប្រកាន់ និងដីកាសម្រេចឃុំខ្លួន និងបន្តឃុំខ្លួនលោក កាំង ហ្គេកអ៊ាវ បានធ្វើឡើងដោយផ្អែកទៅលើ [ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ]" និងផ្អែកទៅលើឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការ ។ ថាតើអង្គហេតុទាំងនេះ បន្ថែមជាមួយកត្តាផ្សេងៗទៀតដូចជាលក្ខណៈរបស់អង្គជំនុំជម្រះវិសាមញ្ញជាតុលាការជាតិ គឺគ្រប់គ្រាន់ដើម្បីបង្កើតជា"ការឃុំខ្លួនដែលមានប្រយោជន៍"របស់ឌុចដោយអង្គជំនុំជម្រះឬអត់ នេះជាសំណួរដែលគួរតែពិនិត្យមើល ។

១៦) ប្រសិនបើតុលាការអន្តរជាតិមានការឃុំខ្លួនដែលមានប្រយោជន៍របស់ជនជាប់ចោទនោះ វារួមចំណែកការទទួលខុសត្រូវជាមួយរដ្ឋាភិបាលក្នុងស្រុកចំពោះការរំលោភបំពានលើសិទ្ធិរបស់ចុងចោទ ។ ជាក់ស្ដែង នៅក្នុងសំណុំរឿង*កាជេលីជេលី* (Kajelijeli) ជនជាប់ចោទត្រូវចាប់ខ្លួនដោយអជ្ញាធរក្នុងស្រុកតាមរយៈការស្នើសុំដោយអយ្យការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងត្រូវឃុំខ្លួនអស់រយៈពេលជិត៣ខែ ទម្រាំតែមានដីកាចាប់ខ្លួនចេញដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ឬទម្រាំតែត្រូវបានចោទប្រកាន់ ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានសម្រេចថា ទាំងលក្ខន្តិកៈបង្កើតតុលាការនេះ ឬច្បាប់នីតិវិធីរបស់ខ្លួនមិនបានបញ្ជាក់អំពី"របៀប និងមធ្យោបាយ"នៃការចាប់ខ្លួនរបស់ជនជាប់ចោទឡើយ ។ ផ្ទុយទៅវិញ "វាគឺស្ថិតនៅលើរដ្ឋដែលត្រូវបានគេស្នើសុំជាអ្នកសម្រេចអំពីរបៀបក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅក្រោមច្បាប់អន្តរជាតិ" ។ ទន្ទឹមនឹងនោះដែរ "មានបន្ទុករួមគ្នាទាក់ទងនឹងការការពារសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យនៅក្នុងសហប្រតិបត្តិការអន្តរជាតិទាក់ទងនឹងបញ្ហាឧក្រិដ្ឋកម្ម" ។ ដោយសារតែអយ្យការមាន"ការទទួលខុសត្រូវត្រួតគ្នា"ជាមួយរដ្ឋសហការ នៅពេលដែលអយ្យការចាប់ផ្ដើមពិនិត្យសំណុំរឿង អយ្យការត្រូវតែធានាថា "សំណុំរឿងនេះបញ្ជូនទៅធ្វើការជំនុំជម្រះតាមរបៀបមួយដែលគោរពដល់សិទ្ធិរបស់ជនជាប់ចោទ" ។ ដូច្នេះ៖

> ប្រសិនបើជនជាប់ចោទ [ឬ ជនសង្ស័យ] ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដោយរដ្ឋមួយ តាមសំណើរ *ឬអំណាចរបស់*តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា សូម្បីតែជនជាប់ចោទមិនទាន់ស្ថិតនៅក្នុងការឃុំខ្លួនជាក់ស្ដែងរបស់តុលាការក៏ដោយ តុលាការនេះមានការទទួលខុសត្រូវក្នុងការផ្ដល់ការបន្ធូរបន្ថយ ដែលអាចធ្វើទៅបានដើម្បីព្យាយាមកាត់បន្ថយការរំលោភបំពានផ្សេងៗតាមដែលអាចធ្វើទៅបាន ។

00154479

១៧) ទាំងច្បាប់លក្ខន្តិកៈបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ពុំបានចែងអំពីសិទ្ធិទទួលបានដំណោះស្រាយយ៉ាងមានប្រសិទ្ធិភាពចំពោះការរំលោភបំពានលើដំណើរការជំនុំជម្រះទេ ក៏ប៉ុន្តែ សាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដាថ្មីៗនេះបានថ្លែងថា ខ្លួនមានអំណាច"ជាប់មកជាមួយ"ក្នុងការផ្ដល់ដំណោះស្រាយដែលរួមមានទាំងការផ្ដល់ជម្ងឺចិត្ត ។ នៅពេលដែលសិទ្ធិជនជាប់ចោទ"ត្រូវរំលោភបំពាន ក៏ប៉ុន្តែមិនធ្ងន់ធ្ងរពេកនោះ" តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា នឹងបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទនោះរកឃើញថា មានទោសទណ្ឌ ។ ដូចអង្គជំនុំជម្រះវិសាមញ្ញដែរ តុលាការអន្តរជាតិបានកំណត់រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន នឹងអនុញ្ញាត ឬក៏តម្រូវឲ្យមានការដោះលែងនៅពេលផុតរយៈពេលកំណត់នេះ ។

**ឃ) ដោយមិនគិតពីលក្ខណៈគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រសិនបើការរំលោភបំពានសិទ្ធិរបស់ឧុចធ្ងន់ធ្ងរគ្រប់គ្រាន់ អង្គជំនុំជម្រះវិសាមញ្ញមានឆន្ទានុសិទ្ធិក្នុងការបញ្ឈប់ដំណើរការជំនុំជម្រះ ។**

១៨) ដូចដែលបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត នៅពេលមានការចោទប្រកាន់ធ្ងន់ធ្ងរអំពីការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ឃុំឃាំង តុលាការបានពិចារណាថាតើការរំលោភបំពាននោះធ្ងន់ធ្ងរពេករហូតដល់ធ្វើឲ្យការបន្តដំណើរការជំនុំជម្រះ នឹង"កាត់បន្ថយសុចរិតភាពនៃដំណើរការយុត្តិធម៌ និងអយុត្តិធម៌ចំពោះជនជាប់ចោទ ។ នៅក្រោមទ្រឹស្ដីនៃ"ការរំលោភបំពានដំណើរការជម្រះ" សូម្បីតែនៅពេលដែលតុលាការមិនរួមចំណែកនៅក្នុងការរំលោភបំពានលើដំណើរការជំនុំជម្រះក៏ដោយ តុលាការមានឆន្ទានុសិទ្ធិក្នុងការបញ្ឈប់ដំណើរការជំនុំជម្រះព្រហ្មទណ្ឌ ។ ទ្រឹស្ដីនេះគឺមានទំនាក់ទំនងទៅនឹងគំនិតដែលថា "តុលាការមានអំណាចគ្រប់គ្រងដែលអាចយកមកប្រើប្រាស់ដើម្បីបុព្វហេតុយុត្តិធម៌ ដោយមិនគិតដល់ការរំលោភបំពានជាក់លាក់ណាមួយ" ។

១៩) ការលើកលែងការចោទប្រកាន់គឺជាមធ្យោបាយសមរម្យ តែនៅពេលដែលមានការរំលោភបំពានធ្ងន់ធ្ងរជាពិសេស ក៏ប៉ុន្តែ ទ្រឹស្ដីនៃការរំលោភបំពានដំណើរការជំនុំជម្រះនេះមិនមែនប្រើប្រាស់នៅក្នុងសំណុំរឿង"ទារុណកម្ម ឬការធ្វើទុក្ខទោសធ្ងន់ធ្ងរ"នោះទេ ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានថ្លែងថា ការលើកលែងការចោទប្រកាន់ និងការដោះលែងដោយគ្មានលក្ខខណ្ឌ អាចសមរម្យនៅពេលដែលសិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពានធ្ងន់ធ្ងរតាមរយៈការពន្យារពេល ឬ"សកម្មភាពកុហកឬមិនស្របច្បាប់ដោយអយ្យការ" ។សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស

រ៉ាន់ដា បានថ្លែងថា "វាជាកត្តាជាច្រើនបូកបញ្ចូលគ្នា ដែលមិនមែនមានកត្តាតែមួយនោះទេ" ដែលនាំទៅដល់ការអនុវត្តដំណោះស្រាយបែបនេះ ។ នៅក្នុងសំណុំរឿង *បារ៉ាយ៉ាវីហ្សា* (Barayagwiza Case) សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា បានថ្លែងថាការប្រើប្រាស់ទ្រឹស្តីនេះសមរម្យនៅពេលដែលមាន"ការពន្យាពេលជាបន្តទៀត ដែលហាក់បីដូចជាកើតឡើងនៅស្ទើរតែគ្រប់ដំណាក់កាលទាំងអស់" នៃសំណុំរឿងនេះ ការរំលោភបំពានលើសិទ្ធិជនជាប់ចោទម្តងហើយម្តងទៀត និងការខកខានដោយអយ្យការក្នុងការចោទប្រកាន់ដែល"ស្ទើរនឹងការធ្វេសប្រហែស" ។ សាលាឧទ្ធរណ៍នេះបានសង្កត់ធ្ងន់ថាៈ

> វាមិនទាក់ទងទេដែលថា មានតែមួយផ្នែកតូចប៉ុណ្ណោះនៃរយៈពេលទាំងមូលនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ដែលបណ្តាលមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ដោយសារតែវាជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងមិនមែនជាអង្គភាពផ្សេងទៀតដែលកំពុងតែជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ។

(២០) សំណុំរឿងដែលសមនឹងទទួលបានការលើកលែងការចោទប្រកាន់ "គឺវិសាមញ្ញ ហើយនៅក្នុងកាលៈទេសៈទូទៅ ដំណោះស្រាយដោយការលើកលែងចោទប្រកាន់នេះនឹង...គ្មានសមាមាត្រ" ។ ដោយមូលហេតុនេះ នៅក្នុងសេចក្តីសម្រេចក្រោយមកទៀតនៅក្នុងសំណុំរឿង *បារ៉ាយ៉ាវីហ្សា* ដែល សាលាឧទ្ធរណ៍បានថ្លែងថា អង្គហេតុថ្មី"បានកាត់បន្ថយការខកខានរបស់ព្រះរាជអាជ្ញា ក៏ដូចជាបានកាត់បន្ថយស្ថានភាពធ្ងន់ធ្ងរនៃការរំលោភសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍" ។ ដូច្នេះ សាលាឧទ្ធរណ៍នេះបានថ្លែងថាការលើកលែងការចោទប្រកាន់គឺ"វិសមាមាត្រសម្រាប់ព្រឹត្តការណ៍ទាំងនោះ" និងបានចេញដីកាផ្តល់សំណងជម្ងឺចិត្តជំនួសវិញ ។ ក៏ប៉ុន្តែ ជាពិសេស សាលាឧទ្ធរណ៍នេះក៏បាន"បញ្ជាក់ផងដែរថា [សេចក្តីសម្រេចលើកមុន]...គឺសំអាងទៅលើអង្គហេតុដែលមាននៅពេលនោះ" ។

## II. បើទោះបីជាការឃុំខ្លួនដោយតុលាការយោធាបណ្តាលមកពីអង្គជំនុំជម្រះវិសាមញ្ញឬអត់ អង្គជំនុំជម្រះវិសាមញ្ញមានបុព្វសិទ្ធិ និងកាតព្វកិច្ចពិនិត្យមើលឡើងវិញអំពីភាពស្របច្បាប់នៃការឃុំខ្លួននោះ។

00154481

ក) ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្តល់អំណាចដល់អង្គជំនុំជម្រះនេះក្នុងការពិនិត្យមើល និងបកស្រាយនីតិវិធីព្រហ្មទណ្ឌកម្ពុជាក្នុងស្រុក ។

២១) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចតាមច្បាប់អាចធ្វើការពិនិត្យមើល និងបកស្រាយនីតិវិធីកម្ពុជា ហើយនៅពេលចាំបាច់ អាចសម្រេចថា តើនីតិវិធីទាំងនេះត្រូវបានអនុវត្តស្របតាមច្បាប់អន្តរជាតិដែរឬទេ ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញបានចែងថា ការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំ ជម្រះត្រូវធ្វើឡើងដោយស្របតាម“ច្បាប់នីតិវិធី[កម្ពុជា]ដែលមានស្រាប់” ។ ជាងនេះទៅទៀត “លក្ខខណ្ឌសម្រាប់ការចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទត្រូវស្របទៅនឹងច្បាប់ជាធរមានដែលមានស្រាប់” ។

> ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របឬមិនសមស្របទៅនឹងនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំនៅក្នុងនីតិវិធីដែលបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ។

២២) បន្ថែមទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានអនុម័តកាលពីខែកក្កដា ឆ្នាំ២០០៧ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថ្មីមួយទៀតបានចូលជាធរមាននៅក្នុងខែសីហា ឆ្នាំ២០០៧ ។ នៅមុនពេលអនុម័តនីតិវិធីទាំងនេះ មានក្រមព្រហ្មទណ្ឌកម្ពុជាពីរៈ ច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ និងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ។ នៅក្នុងឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានប្រកាសឲ្យប្រើច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្នដែលអនុញ្ញាតឲ្យបុគ្គលដែលជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឬបទប្រល័យពូជសាសន៍ អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន“រយៈពេលមួយឆ្នាំ”មិនឲ្យលើស “រយៈពេលសរុបពាឆ្នាំទេ” ។ ឌុចត្រូវបានឃុំខ្លួនដោយច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ននេះអស់រយៈពេល៨ឆ្នាំ រហូតដល់ពេលត្រូវផ្ទេរទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ។

២៣) វិធានផ្ទៃក្នុងបានចង្អុលបង្ហាញថា វិធាននេះត្រូវបានបង្កើតឡើងដើម្បីគោលបំណង“ពង្រឹង”នីតិវិធីកម្ពុជា មិនមែនដើម្បីជំនួសនីតិវិធីកម្ពុជាទេ ។ “នីតិវិធីជាធរមានដែលមានស្រាប់”ដែលនឹងត្រូវប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ អាចនិយាយបានថា មានមិនត្រឹមតែវិធានផ្ទៃក្នុងទេ ប៉ុន្តែ មានទាំងច្បាប់

នីតិវិធីកម្ពុជាទាំងអស់ ដែលទាក់ទងទៅនឹងបញ្ហាដែលកើតឡើងនៅក្នុងការជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញជាពិសេសបញ្ហាទាក់ទងនឹងដំណើរការព្រហ្មទណ្ឌដែលកើតឡើងនៅមុនពេលអនុម័តវិធានផ្ទៃក្នុង ។

២៤) ជាពិសេស ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញមិនត្រឹមតែអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញអនុវត្តច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជាទេ ច្បាប់នេះបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញរួមទាំងសហចៅក្រមស៊ើបអង្កេតផងដែរ ត្រូវបានរំពឹងថានឹងធ្វើការបកស្រាយនីតិវិធីទាំងនេះ និងសម្រេចអំពីភាពសមស្របរបស់នីតិវិធីទាំងនេះទៅនឹងបទដ្ឋានអន្តរជាតិ ដែលអាចនិយាយបានថា រួមទាំងបទដ្ឋានទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ និងបទដ្ឋានទាំងឡាយដែលតុលាការព្រហ្មទណ្ឌអន្តរជាតិគោរពតាមផងដែរ ។ ការណ៍នេះបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតនូវអំណាចក្នុងការបកស្រាយច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្នឆ្នាំ១៩៩៩ ក៏ដូចជាច្បាប់អ៊ុន គាក់ដែលតម្រូវឲ្យមានការដោះលែង "ជាបន្ទាន់" នៅពេលដែលមិនបានគោរពតាមនីតិវិធីឃុំខ្លួនបណ្តោះអាសន្ន ។

២៥) អណត្តិរបស់តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប (European Court of Human Rights) អាចយកមកប្រដូចនឹងអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងបរិបទនេះ ។ តុលាការទាំងពីរនេះមានអំណាចសម្រេចថាតើច្បាប់មួយសមស្របទៅនឹងបទដ្ឋានអន្តរជាតិឬអត់ ក៏ប៉ុន្តែ មិនមែនពិនិត្យមើលឡើងវិញអំពីការបកស្រាយច្បាប់នោះដោយតុលាការក្នុងស្រុកទេ ។ដូច្នេះ វាសំខាន់ដែលតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានចែងថា មាត្រា៥(១)នៃអនុសញ្ញាអ៊ឺរ៉ុប (European Convention) បានផ្តល់អំណាចឲ្យខ្លួន "អាចពិនិត្យមើលអំពីការគោរពច្បាប់ក្នុងស្រុកដោយអាជ្ញាធរជាតិទាំងឡាយ" ។ មាត្រានេះចែងខ្លះៗថា "គ្មាននរណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួន លើកលែងតែក្នុងករណីខាងក្រោម និងលើកលែងតែការដកហូតសេរីភាពនោះស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់" ។ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបាន ចែងថា ភាសាសរសេរនេះសំដៅមិនត្រឹមតែដល់ការណ៍ដែលថា ច្បាប់ក្នុងស្រុកត្រូវតែស្របនឹងអនុសញ្ញាអ៊ឺរ៉ុបទេ ក៏ប៉ុន្តែថែមទាំងសំដៅដល់កាតព្វកិច្ចរបស់រដ្ឋជាសមាជិកក្នុងការគោរពច្បាប់ក្នុងស្រុកទៀតផង ។ ដោយសារមូលហេតុនេះ:

> បើទោះបីជាមិនធម្មតា ដែលភារកិច្ចរបស់តុលាការក្នុងការពិនិត្យមើលអំពីការគោរពច្បាប់ក្នុងស្រុកដោយអាជ្ញាធរជាតិក៏ដោយ...ក៏ផ្ទុយទៅវិញ ដូចនៅទីនេះ វាទាក់ទងនឹងបញ្ហានៅពេលដែលអនុសញ្ញាអ៊ឺរ៉ុបបានយោងដោយផ្ទាល់ត្រឡប់ទៅច្បាប់នោះវិញ ។ ដោយសារនៅក្នុងបញ្ហាទាំងនោះ ការមិនគោរពច្បាប់ក្នុងស្រុកបណ្តាលឲ្យមានការរំលោភលើ

00154483

អនុសញ្ញាអឺរ៉ុប ដែលជាលទ្ធផលតុលាការអាច និងគួរតែអនុវត្តអំណាចត្រួតពិនិត្យខ្លះរបស់ខ្លួន ។

២៦) ស្រដៀងគ្នានេះដែរ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានបកស្រាយភាសាសរសេរនៅក្នុងលក្ខន្តិកៈក្រុងរ៉ូមដែលចែងថា បុគ្គលដែលត្រូវចាប់ខ្លួន «ត្រូវជំនុំជម្រះឲ្យបានទាន់ពេលវេលាដោយអជ្ញាធរដែលមានសមត្ថកិច្ចជំនុំជម្រះនៅក្នុងរដ្ឋឃុំខ្លួន ដែលត្រូវសម្រេចដោយយោងទៅតាមច្បាប់របស់រដ្ឋនោះថា ... បុគ្គលនោះត្រូវបានចាប់ខ្លួនស្របតាមដំណើរការត្រឹមត្រូវ...និង...សិទ្ធិ[របស់ពួកគេ]ត្រូវបានគោរព» ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានច្រានចោលអំណះអំណាងរបស់ជនជាប់ចោទដែលថា មាត្រានេះបានផ្តល់អំណាចឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រេចអំពីភាពត្រឹមត្រូវនៃសេចក្តីសម្រេចរបស់អជ្ញាធរក្នុងស្រុក ប៉ុន្តែបានថ្លែងថា «កិច្ចការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិគឺត្រូវមើលថា តើដំណើរការដែលមានចែងដោយច្បាប់[ក្នុងស្រុក]ត្រូវបានគោរពត្រឹមត្រូវឬទេ និងថាតើសិទ្ធិរបស់បុគ្គលដែលត្រូវបានចាប់ខ្លួនត្រូវបានគេគោរពត្រឹមត្រូវឬអត់» ។

២៧) ដូចគ្នាដែរ ដោយសារច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ «បានយោងត្រឡប់ទៅ» ច្បាប់នីតិវិធីកម្ពុជាវិញទាក់ទងនឹងបញ្ហាចាប់ខ្លួន និងឃុំខ្លួន អង្គជំនុំជម្រះវិសាមញ្ញមានអំណាចដូចមានចែងនៅក្នុងច្បាប់ ក្នុងការសម្រេចថាតើតុលាការកម្ពុជាក្នុងស្រុកបានគោរពតាមនីតិវិធីក្នុងស្រុកដែរឬអត់ ។

**១) អង្គជំនុំជម្រះវិសាមញ្ញមានអំណាចពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុន និងមានអំណាចក្នុងការផ្តល់ដំណោះស្រាយដែលមានប្រសិទ្ធិភាព ។**

២៨) ដោយសារតែភាពជិតស្និទនៃសិទ្ធិទទួលបាននូវការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំឃាំង អង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តាធិការក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួន ។ តាមការពិត ក្រមព្រហ្មទណ្ឌកម្ពុជាបានចែងថា «ចៅក្រមទាំងឡាយដែលទទួលបានពាក្យបណ្តឹងទាក់ទងនឹងការឃុំខ្លួនខុសច្បាប់ត្រូវតែធ្វើការពិនិត្យមើលជាបន្ទាន់» ។ នៅក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួននៅក្នុងសំណុំរឿងពីរនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សាលាឧទ្ធរណ៍ជឿជាក់ថា ការឃុំខ្លួនជនជាប់ចោទដោយអជ្ញាធរក្នុងស្រុកបណ្តាលមកពីព្រះរាជអាជ្ញារបស់តុលាការនេះក្នុងសំណុំរឿងមួយ ក៏ប៉ុន្តែ ក្នុងសំណុំរឿងមួយទៀតមិនមានរឿងបែបនេះកើតឡើងទេ ។ ប៉ុន្តែ នៅក្នុងសំណុំរឿងទាំងពីរនេះ សាលាឧទ្ធរណ៍នេះបានបញ្ជាក់អំពីសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទក្នុងការ «ស្វែងរក

00154484

ការត្រួតពិនិត្យមើលសកម្មភាពរបស់អជ្ញាធរឃុំខ្លួនពីសំណាក់មន្ត្រីយុត្តិធម៌ឯករាជ្យ» ។ សាលាឧទ្ធរណ៍នេះបានថ្លែងថា:

> តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ត្រូវតែជំនុំជម្រះ[ការជំទាស់ទៅនឹងភាពស្របច្បាប់នៃការឃុំខ្លួន] និងត្រូវតែចេញសេចក្តីសម្រេចដោយគ្មានការពន្យារពេល ដូចដែលមានចែងនៅក្នុងលិខិតូបករណ៍សំខាន់ៗនៃច្បាប់សិទ្ធិមនុស្ស ។ ប្រសិនបើមានបណ្តឹងជំទាស់ ហើយមិនត្រូវបានជំនុំជម្រះ សាលាឧទ្ធរណ៍នឹងសម្រេចថា សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទត្រូវបានរំលោភបំពាន ។

២៩) សាលាដំបូងនៃតុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសអតីតយូហ្គោស្លាវី បានថ្លែងស្រដៀងគ្នាថា «ប្រាកដណាស់ តុលាការនេះមានទាំងអំណាច និងនីតិវិធីក្នុងការដោះស្រាយបណ្តឹងជំទាស់ទៅនឹងភាពស្របច្បាប់នៃការឃុំខ្លួនអ្នកជាប់ឃុំឃាំង» ។ សិទ្ធិនេះជារបស់«បុគ្គលដែលត្រូវបានឃុំឃាំងដែលសំណុំរឿងរបស់ខ្លួនត្រូវបានបញ្ជូនទៅកាន់សាលាដំបូង» ។ «នៅពេលដែល...សំណើរ[បឋម]ត្រូវបានដាក់ជូនសាលាដំបូង ព្រះរាជអាជ្ញាមានសិទ្ធិផ្ញើការឆ្លើយតប ហើយបន្ទាប់មក សាលាដំបូងនឹងផ្តល់នូវសេចក្តីសម្រេចរបស់ខ្លួន» ។

៣០) ប្រសិនបើអំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួនឌុចកាលពីមុនមិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះវិសាមញ្ញគួរតែគិតថា ខ្លួនមានអំណាចនេះមកជាមួយ ។ នៅក្នុងសំណុំរឿងរ៉ូម៉ាគូបា (Rwamakuba) សាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានថ្លែងថា «ទាំងច្បាប់លក្ខន្តិកៈ និងច្បាប់នីតិវិធីរបស់ខ្លួនមិនបានចែងអំពីសិទ្ធិផ្តល់ដំណោះស្រាយមានប្រសិទ្ធិភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទេ» ។ ក៏ប៉ុន្តែ តុលាការនេះបានចែងថា អំណាចក្នុងការផ្តល់ដំណោះស្រាយមានប្រសិទ្ធិភាពនេះ«កើតចេញពីឥទ្ធិពលរួមគ្នានៃអំណាចជាប់មកជាមួយតុលាការនេះ និងកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពបទដ្ឋានសិទ្ធិមនុស្សដែលទទួលស្គាល់ជាទូទៅ» ។អំណាចដែលមានមកជាមួយតុលាការនេះ«គឺមានសម្រាប់តុលាការនេះតែម្តងព្រោះវាមានសារៈសំខាន់ណាស់នៅក្នុងការបំពេញតួនាទីតុលាការនេះ ដែលរួមទាំងការគ្រប់គ្រងត្រឹមត្រូវនិងសមរម្យនូវដំណើរការយុត្តិធម៌» ។ ប្រភពបន្ថែមមួយទៀតគឺលក្ខណៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ដែលជា«អង្គភាពបន្ទុំប្រភេទពិសេសមួយរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ» ដែល«ត្រូវតែគោរព និងធានាថាមានការគោរពបទដ្ឋានសិទ្ធិមនុស្ស

ដែលមានទទួលស្គាល់ជាទូទៅ» ។ ដូចដែលបានពិភាក្សាខាងលើ អង្គជំនុំជម្រះវិសាមញ្ញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអង្គការសហប្រជាជាតិ និងជាយន្តការមួយបង្កើតឡើងដើម្បីលើកកម្ពស់យុត្តិធម៌អន្តរជាតិ ។ ជាងនេះទៅទៀត ដោយសារទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធយុត្តិធម៌កម្ពុជា អង្គជំនុំជម្រះវិសាមញ្ញប្រហែលជាមានកាតព្វកិច្ចកាន់តែសំខាន់ថែមទៀត ក្នុងការធានាឲ្យមានការគោរពសិទ្ធិរបស់ជនជាប់ឃុំខ្លួនបណ្ដោះអាសន្ននេះ ។ ដូចនេះ អង្គបុរេជំនុំជម្រះគួរតែសម្រេចថា សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសម្រេចអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុច និងក្នុងការពិចារណាឥទ្ធិពលនៃការឃុំខ្លួននេះថាតើវាសមរម្យនឹងធ្វើការដោះលែងបណ្ដោះអាសន្នឬទេ ។

**គ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានកាតព្វកិច្ចក្នុងការសម្រេចថា តើការឃុំខ្លួនកាលពីមុនរបស់ឌុចគឺស្របច្បាប់ និងមិនមែនដោយបំពានឬទេ ។**

៣១) នៅក្នុងការវាយតម្លៃអំពីភាពស្របច្បាប់នៃការឃុំខ្លួន សំណួរដំបូងដែលត្រូវដោះស្រាយទាំងតុលាការសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិគឺក្នុងករណីដែលវាស្របច្បាប់ ឬមិនស្របច្បាប់ ។ ដើម្បីឲ្យការឃុំខ្លួនមួយស្របច្បាប់ ការឃុំខ្លួននោះត្រូវតែធ្វើឡើង«ដោយមូលហេតុស្របច្បាប់ និងស្របទៅនឹងនីតិវិធីតាមច្បាប់» ។ ជាឧទាហរណ៍ គណៈកម្មាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (Inter-American Commission on Human Rights) បានថ្លែងថា ការឃុំខ្លួនទាំងឡាយណាដែលហួសពីរយៈពេលកំណត់ដោយច្បាប់«គួរតែត្រូវចាត់ទុកថាមិនស្របច្បាប់» ព្រោះ«បទដ្ឋានណាមួយដែលអនុញ្ញាតឲ្យមានការដោះលែងអ្នកទោសម្នាក់ពីមន្ទីរឃុំឃាំង មិនអាចត្រូវបានយកមកបកស្រាយថាអាចអនុញ្ញាតឲ្យធ្វើការពន្យារពេលនៃការឃុំខ្លួន ដោយសារមូលហេតុការពារផ្សេងៗឲ្យយូរជាងអ្វីដែលក្រមនីតិវិធីគិតថាសមរម្យនោះទេ» ។ ជាលទ្ធផល ការពន្យាររយៈពេលឃុំខ្លួនត្រូវតែ«ត្រួតពិនិត្យមើលយ៉ាងតឹងតែង» ។ មិនត្រឹមតែការឃុំខ្លួនត្រូវតែស្របច្បាប់ប៉ុណ្ណោះទេ វាត្រូវតែ«ដោយមិនបំពាន»ទៀតផង ។ ការឃុំខ្លួនត្រូវចាត់ទុកថាបំពារបំពាននៅពេលដែលការឃុំខ្លួននោះមិន«សមហេតុសមផល» និងមិន«ចាំបាច់»នៅក្រោមកាលៈទេសៈនោះ ។ ដូច្នេះ ការវាយតម្លៃអំពីភាពស្របច្បាប់នៃការឃុំខ្លួនតម្រូវឲ្យមានទាំងការសម្រេចថាតើនីតិវិធីត្រូវបានគេគោរពឬទេ និង ទាំង«ភាពសមហេតុសមផលនៃ....ភាពស្របច្បាប់នៃគោលបំណងដែលសម្រេចឲ្យមានការចាប់ខ្លួន និងឃុំខ្លួននោះ» ។

៣២) នៅក្នុងសំណុំរឿង*អាល់ម៉ាន់ និង ប្រទេសបារាំង* *(Altmann v. France)* គណៈកម្មាការសិទ្ធិមនុស្សអ៊ឺរ៉ុប *(European Commission on Human Rights)* បានសម្រេចថាតើប្រទេសបារាំងទទួលខុសត្រូវចំពោះនីតិវិធីបត្យាប័នដែលត្រូវចោទថាមិនស្របច្បាប់ ប្រើប្រាស់ដោយប្រទេសបូលីវី (Bolivia)ដែលនាំឲ្យមានការឃុំខ្លួនម្ចាស់បណ្ដឹងនេះនៅក្នុងប្រទេសបារាំង ។ នៅក្នុងការសម្រេចថាតើ

00154486

មាន«ការសហការយ៉ាងជិតស្និទ»រវាងរដ្ឋទាំងពីរនេះដូចដែលបានលើកឡើងដោយម្ចាស់បណ្តឹង គណៈកម្មាការបានពិនិត្យមើលថា តើច្បាប់បារាំងដែលគ្រប់គ្រងការឃុំខ្លួននៅក្នុងប្រទេសបារាំងនោះត្រូវគេគោរពត្រឹមត្រូវ និងមិនបំពារបំពានដែរឬទេ ។ ដោយសារលក្ខខណ្ឌនេះត្រូវបានបំពេញ គណៈកម្មាធិការនេះបានសម្រេចថា មិនមានការរំលោភបំពានលើអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (European Convention on Human Rights)ទេ ។

៣៣) នៅក្នុងសំណុំរឿងលូបាងហ្គា (Lubanga) តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានពិចារណាអំពីភាពស្របច្បាប់នៃការចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទដោយសាធារណរដ្ឋកុងហ្គោ (Democratic Republic of the Congo) នៅក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់ជនជាប់ចោទទៅនឹងយុត្តាធិការរបស់តុលាការ ។ អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចថា នៅពេលដែលពុំមានការបំពានលើដំណើរការទេ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិនិត្យមើលអំពីការរំលោភសិទ្ធិជនជាប់ចោទ កាលពីនៅក្រោមការឃុំខ្លួនក្រោមយុត្តាធិការជាតិ «តែនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថា មាន*ការសហការយ៉ាងជិតស្និទ*រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និង...អាជ្ញាធរ[ក្នុងស្រុក]» ។ នៅពេលពិនិត្យមើលឡើងវិញ សាលាឧទ្ធរណ៍រកពុំឃើញមានការចូលរួមដោយអយ្យការនៅក្នុងការឃុំខ្លួនជនជាប់ចោទនៅក្នុងប្រទេសឃុំខ្លួនគាត់ទេ ។ ប៉ុន្តែ សាលាឧទ្ធរណ៍បានសម្រេចថា តាមលក្ខន្តិកៈបង្កើតតុលាការ តុលាការនេះមានអាណត្តិ«មើលថាតើ ដំណើរការដែលចែងដោយច្បាប់[ជាតិ]ត្រូវបានគេគោរពត្រឹមត្រូវដែរឬទេ និងថាតើសិទ្ធិបុគ្គលត្រូវចាប់ខ្លួនត្រូវបានគោរពត្រឹមត្រូវដែរឬទេ» ។ សាលាឧទ្ធរណ៍បានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះ តាមការពិត «បានសម្រេចថា ដំណើរការអនុវត្តគឺសមស្របតាមច្បាប់របស់ប្រទេសកុងហ្គោ» ហើយសាលាឧទ្ធរណ៍នេះបានសម្រេចថា «ពុំមានអ្វីផ្ទុយទៅនឹងការលើកឡើងនេះ.... [ឬ]អាចបញ្ជាក់ថា ការចាប់ខ្លួនគាត់ ឬការបង្ហាញខ្លួនគាត់នៅចំពោះមុខអាជ្ញាធរកុងហ្គោ មានការរំលោភបំពានណាមួយលើសិទ្ធិរបស់គាត់ឡើយ» ។

**ឃ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានកាតព្វកិច្ចពិនិត្យមើលអំពីរយៈពេលនៃការឃុំខ្លួនកាលពីមុននៅក្នុងការសម្រេចពីភាពស្របច្បាប់នៃការឃុំខ្លួនជាបន្ត ។**

៣៤) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលទើបតែអនុម័តថ្មីៗនេះបានចែងថា «ជាគោលការណ៍ទូទៅសេរីភាពរបស់ជនជាប់ចោទត្រូវតែផ្តល់ឲ្យ» ប៉ុន្តែ «នៅក្នុងករណីពិសេស ជនជាប់ចោទអាចត្រូវឃុំខ្លួនជាបណ្តោះអាសន្ន» ។ ដូចគ្នាដែរ តុលាការសិទ្ធិមនុស្សបានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាករណីលើកលែង និងមិនត្រូវឲ្យហួសរយៈពេលចាំបាច់ឡើយ ។ នៅក្នុងការវាយតម្លៃអំពីភាពសមរម្យនៃការបន្តឃុំខ្លួន តុលាការសិទ្ធិមនុស្សទាំងនោះបានអនុវត្តនូវការសាកល្បងមួយដែលព្យាយាមធ្វើឲ្យមានតុល្យភាព ។

ជាក់ស្តែង តុលាការសិទ្ធិមនុស្សអឺរ៉ុប (European Court of Human Rights) បានថ្លែងថា «ពីដំបូងវាស្ថិតនៅក្រោមអាជ្ញាធរតុលាការក្នុងស្រុក ក្នុងការ...ពិនិត្យមើលគ្រប់លក្ខខណ្ឌទាំងអស់ដែលគាំទ្រ ឬប្រឆាំងទៅនឹងតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈដែលអាចដោះសារបាន ....ចំពោះភាពមិនសមស្របទៅនឹងវិធាននៃការគោរពសេរីភាពបុគ្គល» ។

៣៥) តុលាការអន្តរជាតិជាទូទៅបានចាត់ទុកការដោះលែងថា ជាករណីលើកលែង ប៉ុន្តែ នៅប៉ុន្មានឆ្នាំថ្មីៗនេះតុលាការទាំងនេះក៏បានប្រើប្រាស់ការសាកល្បងមួយ ដែលព្យាយាមធ្វើឲ្យមានតុល្យភាពនេះដែរ ។ សាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានថ្លែងថា «ការយកចិត្តទុកដាក់[នៃការវាយតម្លៃលើការឃុំខ្លួនបណ្តោះអាសន្ន] ត្រូវតែផ្តោតទៅលើលក្ខខណ្ឌពិសេសនៃសំណុំរឿងនីមួយៗ...កិច្ចការ[របស់សាលាជំនុំជម្រះក្តី] គឺសំខាន់ត្រូវថ្លឹងថ្លែងកត្តាទាំងឡាយដែលមាននៅក្នុងសំណុំរឿងនោះមុនពេលចេញសេចក្តីសម្រេច» ។ ក៏ប៉ុន្តែ តុលាការនេះត្រូវរក្សានូវ«ឆន្ទានុសិទ្ធិយ៉ាងច្រើននៅពេលសម្រេចអំពីទម្ងន់នៃកត្តាទាំងនោះ បន្ទាប់ពីពិចារណាលក្ខខណ្ឌពិសេសរបស់សំណុំរឿងនោះ» ។

៣៦) ទាំងសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថា រយៈនៃការឃុំខ្លួនគឺជា«កត្តាសំខាន់ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិសម្រេចលើសំណើសុំដោះលែងបណ្តោះអសន្ន» ។ ក៏ប៉ុន្តែ នៅពេលដែលការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរ«តម្រូវឲ្យមានសំណាងជម្ងឺចិត្ត» វាមិនមែនជា«បុព្វហេតុល្អសម្រាប់ការដោះលែង[បណ្តោះអាសន្ននោះ]ទេ» ។ នៅក្នុងសំណុំរឿងក្រាជីសនិក (Krajisnik) សាលាដំបូងបានសម្រេចមិនឲ្យមានការដោះលែង នៅពេលដែលរយៈពេលនៃការឃុំខ្លួនមិនហួសរយៈពេលដែលតុលាការសិទ្ធិមនុស្សរកឃើញថាមិនសមហេតុសមផល ការជំនុំជម្រះត្រូវបានរំពឹងថានឹងចាប់ផ្តើមក្នុងរយៈពេលប៉ុន្មានខែទៀត ហើយជនជាប់ចោទមិនបានធ្វើឲ្យសាលាដំបូងនេះជឿជាក់ថា ប្រសិនបើត្រូវដោះលែង គាត់ប្រាកដជានឹងបង្ហាញខ្លួននៅពេលជំនុំជម្រះ និងមិនបង្កជាគ្រោះថ្នាក់ដល់ជនរងគ្រោះ ឬសាក្សី ។ ចៅក្រមរ៉ូប៊ីនសុនបានជំទាស់ទៅនឹងសេចក្តីសម្រេចនេះដោយអះអាងថា បើទោះបីជាការឃុំខ្លួនបណ្តោះអាសន្នរយៈពេលពីរឆ្នាំ ប្រហែលជាមិនយូរពេករហូតដល់រំលោភបទដ្ឋានសិទ្ធិមនុស្សបន្ថែមលើការធានាដែលជនរងគ្រោះបានផ្តល់ទាក់ទងនឹងការបង្ហាញខ្លួនសម្រាប់ការជំនុំជម្រះ វាគួរតែអាចគ្រប់គ្រាន់សម្រាប់ការដោះលែងបាន ។

00154488

៣៧) នៅក្នុងសំណុំរឿង *បាហ្គោសូរ៉ា*[ចុងចោទមានច្រើននាក់នៅក្នុងសំណុំរឿងនេះ] *(Bagosora et al.)* សាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានពិចារណាថាតើរយៈពេលឃុំខ្លួនរបស់ជនជាប់ចោទ រួមជាមួយកត្តាផ្សេងៗទៀត អាចទទួលបានការដោះលែងបណ្តោះអាសន្នឬទេ ។ ព្រះរាជអជ្ញាបានអះអាងថា រយៈពេលនៃការឃុំខ្លួនមិនគួរគណនាថា មានរយៈពេល៦ឆ្នាំទេ ប៉ុន្តែថាមានរយៈពេល៥ឆ្នាំ៤ខែ ដោយមិនគិតពីរយៈពេលនៃការឃុំខ្លួនដែលមិនមែនជាការទទួលខុសត្រូវដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ ប៉ុន្តែ បើទោះបីជាសាលាដំបូងមិនបានដោះស្រាយការអះអាងនេះឲ្យបានច្បាស់លាស់ក៏ដោយ វាហាក់បីដូចជាបានពិចារណាអំពីរយៈពេលឃុំខ្លួនទាំងមូលរបស់ជនជាប់ចោទមិនមែនត្រឹមតែរយៈពេលដែលទទួលខុសត្រូវដោយសាលាជំនុំជម្រះក្តីនេះទេ ។ ដូច្នេះសាលាដំបូងនេះបានកត់សម្គាល់ថា "នៅក្នុងករណីពិសេស ការឃុំខ្លួនបណ្តោះអាសន្នរយៈពេល៦ឆ្នាំ អាចជាកត្តាមួយក្នុងការសម្រេចអំពីលក្ខខណ្ឌវិសាមញ្ញទាំងឡាយដែលអាចបណ្តាលឲ្យមានការដោះលែងជនជាប់ចោទ" ។

## III. សេចក្តីសន្និដ្ឋាន

៣៨) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការនាំយកយុត្តិធម៌មកឲ្យប្រទេសកម្ពុជា ។ នេះរួមមិនត្រឹមទាំងតួនាទីស្នូលក្នុងការជំនុំជម្រះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងតួនាទីជាគំរូដល់ប្រព័ន្ធយុត្តិធម៌កម្ពុជាទៀតផង ។ អស់រយៈពេល៨ឆ្នាំដែលឌុចត្រូវជាប់ឃុំឃាំងដោយមិនមានការព្យាយាមច្បាស់លាស់ណាមួយនាំយកឌុចទៅជំនុំជម្រះ ។ ឌុចមិនមែនជាអ្នកជាប់ឃុំឃាំងតែម្នាក់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវឃុំខ្លួនរយៈពេលយូរដោយមិនបានទទួលដំណើរការជំនុំជម្រះទេ ។ វាជាភាពស្របច្បាប់ និងជាកេរ្តិ៍ដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលអង្គជំនុំជម្រះនេះត្រូវធ្វើអ្វីគ្រប់យ៉ាង នៅក្រោមអំណាចរបស់ខ្លួនដើម្បីធានាដល់សិទ្ធិរបស់បុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ។ តាមរយៈការធ្វើដូច្នេះ វាអាចធ្វើជាការរួមចំណែកយ៉ាងសម្បើមដល់កិច្ចខិតខំប្រឹងប្រែងផ្សះផ្សាជាតិយូរអង្វែងនៅក្នុងប្រទេសកម្ពុជា ហើយទំហំនៃការផ្សះផ្សាជាតិនេះគឺលាតសន្ធឹងហួសឆ្ងាយពីកិច្ចការដែលមានព្រំដែនកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញ និងរយៈពេលខ្លីនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះទៅទៀត ។

00154489

៣៩) ដើម្បីគោលបំណងនេះ អង្គបុរេជំនុំជម្រះគួរតែរកឲ្យឃើញថា សហចៅក្រមស៊ើបអង្កេតមានយុត្តាធិការក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួនបណ្តោះអាសន្នរបស់ឌុច ហើយអង្គបុរេជំនុំជម្រះខ្លួនឯងគួរតែពិចារណាថា តើសិទ្ធិរបស់ឌុចមានការរំលោភបំពានឬទេ ។ ថាតើអង្គបុរេជំនុំជម្រះរកឃើញថា ការពន្យាពេលក្នុងការជំនុំជម្រះឌុចអាចផ្តល់ឲ្យឌុចនូវការដោះលែងបណ្តោះអាសន្នឬអត់ ឬរកឃើញផ្ទុយទៅវិញថា ដំណោះស្រាយផ្សេងទៀតអាចសមរម្យជាង ដោយពិចារណាអំពីសំណួរនេះពីដំណាក់កាលដំបូងបំផុតនៃការជំនុំជម្រះនឹងបង្ហាញអំពីភាពធ្ងន់ធ្ងរនៃបញ្ហា និងបង្កើតជាគំរូល្អបំផុតសម្រាប់ដំណើរការជំនុំជម្រះត្រឹមត្រូវសម្រាប់តុលាការកម្ពុជាផ្សេងទៀត ។

ផ្តល់សារណាដោយ

(ហត្ថលេខា)

អែន ហេនដែល

ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៧